សុន្ទរកថារបស់**លោក តាខាំម៉ូរ៉ា ហ៊ីរ៉ូស៊ី** ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

២០ មិនា ២០១២

**សូមគោរព ឯឧត្តម ពេជ្រ វាសនា នាយកមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្រ្ត និងឧតុនិយម!**
**សូមគោរព លោក កែវ វ៉យ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់!**
**សូមគោរព លោក ផោក ឈឹម មេឃុំព្រងិល!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពកំពែងក្នុងខេត្តពោធិ៍សាត់។

រដ្ឋាភិបាលជប៉ុនបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យកសិកម្ម តួយ៉ាងការផ្តល់ជំនួយនិងការគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធធារាសាស្រ្ត។ ការកែលម្អប្រព័ន្ធធារាសាស្រ្តបានជួយគាំទ្រដល់រដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចឲ្យបាននូវកំណើនផលិតកម្មស្រូវ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។

ជំនួយថ្ងៃនេះនឹងជួយឲ្យមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់អាចស្តារ និងជួសជុលប្រឡាយកម្រិត២មួយខ្សែដែលមានប្រវែង២,១០០ម៉ែត្រ និងសាងសង់លូទឹកបញ្ចូលស្រែ៤កន្លែង សំណង់ស្នាក់ទឹក២កន្លែង និងប្រឡាយកម្រិត២ថ្មីមួយខ្សែដែលមានប្រវែង១,០៥០ម៉ែត្រ។ យើងរំពឹងថា គម្រោងនេះនឹងជួយកាត់បន្ថយការខូចខាតបណ្តាលមកពីទឹកជំនន់ដែលកើតមានឡើងជារៀងរាល់ឆ្នាំ ព្រមទាំងជួយធ្វើឲ្យប្រសើរឡើងនូវការទទួលបានទឹកស្រោចស្រពរបស់ប្រជាកសិករប្រមាណ៤៩១គ្រួសារនៅក្នុងតំបន់។

ខ្ញុំសង្ឃឹមថាគម្រោងដែលបានចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងថែទាំយ៉ាងត្រឹមត្រូវដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់។ ខ្ញុំក៏សង្ឃឹមផងដែរថា គម្រោងនេះនឹងរួមចំណែកបង្កើនផលិតកម្មស្រូវ ព្រមទាំងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករក្នុងតំបន់គោលដៅ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាព រវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!